ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ: ០០១ សណន

# សេចក្តីណែនាំ

## ស្តីពី

## ការលុបបំបាត់ការបង្កសម្លេងរំខានលើសកម្រិតដោយយានយន្តគ្រប់ប្រភេទ

អនុវត្តតាមច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក និងអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង។

ក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានជាធរមាន សំដៅលុបបំបាត់រាល់សកម្មភាពបែបអនាធិបតេយ្យក្នុងការបញ្ជាយានយន្តគ្រប់ប្រភេទ ដែលបង្កសម្លេងរំខានលើសកម្រិតកំណត់ និងដើម្បីលើកកម្ពស់សេចក្តីថ្លៃថ្នូរក្នុងសង្គម ក្រសួងមហាផ្ទៃ សូមធ្វើការណែនាំដូចខាងក្រោម៖

១.គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ និងរដ្ឋបាលឃុំ សង្កាត់ ត្រូវយកចិត្តទុកដាក់ធ្វើការអប់រំណែនាំ និងផ្សព្វផ្សាយឲ្យបានទូលំទូលាយចំពោះអ្នកប្រើប្រាស់យានយន្តកែច្នៃបំពង់ស៊ីម៉ាំង ឬដោះបំពង់ស៊ីម៉ាំង ឲ្យបញ្ឈប់សកម្មភាពបង្កសម្លេងរំខានដល់អារម្មណ៍ប្រជាពលរដ្ឋ ដោយត្រូវយកយានយន្តទៅបំពាក់បំពង់ស៊ីម៉ាំងឲ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដើម្បីធានាកម្រិតសម្លេងមិនឲ្យលើសពីការកំណត់។ ទន្ទឹមនោះ ត្រូវអប់រំសីលធម៌ សុជីវធម៌ក្នុងការបញ្ជាយានយន្តចំពោះអ្នកប្រើប្រាស់យានយន្តដែលមានកម្រិតសម្លេងខ្លាំង ដើម្បីជៀសវៀងការធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍ និងសិទ្ធិរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងរក្សាបាននូវសេចក្តីថ្លៃថ្នូរក្នុងសង្គម។ កម្រិតសម្លេងដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានជាធរមាន ស្តីពីចរាចរណ៍ផ្លូវគោក និងអនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសម្លេង មានដូចខាងក្រោម៖

ក.ចំពោះទោចក្រយានយន្ត :

- ចំណុះស៊ីឡាំង (CC) < $125cm^3$ (តូចជាង ១២៥សម៣) មិនត្រូវឲ្យលើសពី 85dB(A)
- ចំណុះស៊ីឡាំង (CC) > 125cm3(ចាប់ពី ១២៥សម៣ ឡើង)មិនត្រូវឲ្យលើសពី 90dB(A)។

ខ.ចំពោះរថយន្ត :

- រថយន្តគ្រួសារ និងរថយន្តដែលមានទម្ងន់សរុបអតិបរមាមិនលើសពី ៣,៥តោន មិនត្រូវឲ្យលើសពី 103dB(A)
- រថយន្តដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥តោន និងមានកម្លាំងម៉ាស៊ីនមិនលើស ១៥០KW មិនត្រូវឲ្យលើសពី 105dB(A)
- រថយន្តដែលមានទម្ងន់សរុបអតិបរមាលើសពី ៣,៥តោន និងមានកម្លាំងម៉ាស៊ីនលើសពី ១៥០KW មិនត្រូវឲ្យលើសពី 107dB(A)

- រថយន្តស្ទូច និងរថយន្តបំពាក់ឧបករណ៍ពិសេស **មិនត្រូវឲ្យលើសពី 110dB(A)។**

២. គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមានស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ ត្រូវចុះត្រួតពិនិត្យ និងធ្វើការអប់រំណែនាំដល់ម្ចាស់ទីតាំងកែច្នៃយានយន្តឲ្យបញ្ឈប់រាល់ការកែច្នៃយានយន្តខុសបច្ចេកទេស។ ក្នុងករណីបន្តលបលួចកែច្នៃ ត្រូវចាត់វិធានការរដ្ឋបាល និងវិធានការច្បាប់ឲ្យបានម៉ឺងម៉ាត់។

៣. កងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធគ្រប់ថ្នាក់ ពិសេសស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវចាត់វិធានការបន្ទាន់ ណែនាំដល់កម្លាំងដែលមានសមត្ថកិច្ចក្រោមឱវាទទាំងអស់ ធ្វើការត្រួតពិនិត្យ និងលុបបំបាត់ឲ្យបានរាល់ការប្រើប្រាស់យានយន្តកែច្នៃបំពង់ស៊ីម៉ាំង ឬដោះបំពង់ស៊ីម៉ាំង និងណែនាំដល់អ្នកបញ្ជាយានយន្តបង្កសម្លេងរំខានដល់ប្រជាពលរដ្ឋ ដោយត្រូវ ៖
- យកចិត្តទុកដាក់ត្រួតពិនិត្យលើដងផ្លូវ ទីប្រជុំជន និងធ្វើការឃាត់អប់រំជាបឋមឲ្យបញ្ឈប់សកម្មភាព ព្រមទាំងធ្វើកិច្ចសន្យាយកយានយន្តទៅបំពាក់បំពង់ស៊ីម៉ាំងតាមលក្ខណៈបច្ចេកទេសឲ្យបានត្រឹមត្រូវ។ ទន្ទឹមនោះ ត្រូវណែនាំអំពីសីលធម៌ សុជីវធម៌ក្នុងការបញ្ជាយានយន្តចំពោះអ្នកប្រើប្រាស់យានយន្តដែលមានកម្រិតសម្លេងខ្លាំង ដើម្បីជៀសវៀងធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍ និងសិទ្ធិរស់នៅរបស់ប្រជាពលរដ្ឋទូទៅ និងរក្សាបានភាពថ្លៃថ្នូរក្នុងសង្គម
- ណែនាំដល់កម្លាំងមានសមត្ថកិច្ច ត្រូវបំពេញតាមតួនាទី ភារកិច្ចរបស់ខ្លួនឲ្យបានម៉ឺងម៉ាត់ ហ្មត់ចត់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងគ្មានការលើកលែង។

ទទួលបានសេចក្តីណែនាំនេះ គណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់ថ្នាក់ រដ្ឋបាលឃុំ សង្កាត់ និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ព្រមទាំងសមត្ថកិច្ចពាក់ព័ន្ធ ត្រូវចាត់តាំងអនុវត្តតាមខ្លឹមសារសេចក្តីណែនាំនេះឲ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

*ថ្ងៃ សុក្រ ៣កើត ខែ បុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*

*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ២០២១*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**__ចម្លងជូន ៖__**
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ក្រសួងសាធារណការ និងដឹកជញ្ជូន*
- *ក្រសួងបរិស្ថាន*
- *អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
- *អគ្គស្នងការដ្ឋាននគរបាលជាតិ*
- *អគ្គនាយកដ្ឋានរដ្ឋបាល*
- *ឯកសារ-កាលប្បវត្តិ*